**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្ដីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្ដីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០៧នាក់ និងអ្នកជាសះស្បើយចំនួន ០២នាក់
## នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **៣០១នាក់** (ស្មើនឹង ៩៥,៥៥% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៦១នាក់ និងបុរស ២៤០នាក់។
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **៣១៥នាក់** (ស្ត្រី ៦៦នាក់ និងបុរស ២៤៩នាក់) ។
- អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន **១១នាក់** (ស្ត្រី ០៣នាក់ និងបុរស ០៨នាក់) ។
- អ្នកសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ ចំនួន **៣នាក់** (ស្ត្រី ០២នាក់ និងបុរស ០១នាក់។

**២. មានករណីជាសះស្បើយ៖ ចំនួន ០២នាក់**

- បុរសជនជាតិខ្មែរអាយុ ៥៩ឆ្នាំ មានអាសយដ្ឋាននៅសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ បានធ្វើដំណើរមកពីសហរដ្ឋអាមេរិក បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ ។
- បុរសជនជាតិខ្មែរ អាយុ ៣១ឆ្នាំ ជាអង្គរក្សការពារផ្ទាល់ជូនគណៈប្រតិភូហុងគ្រី ក្នុងព្រឹត្តិការណ៍៣វិច្ឆិកា មានអាសយដ្ឋាន សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**៣. មានករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី ៖ ចំនួន ០៧នាក់**

- **ស្ត្រីជនជាតិខ្មែរអាមេរិកកាំង អាយុ ៣១ឆ្នាំ** មានអាសយដ្ឋានស្នាក់នៅក្រុងប៉ៃលិន ខេត្តប៉ៃលិន ធ្វើដំណើរមកពីសហរដ្ឋអាមេរិក បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ លទ្ធផលធ្វើតេស្តវត្ថុសំណាករបស់បុគ្គលខាងលើ ដែលផ្ដល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។



ទីស្ដីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

សូមកត់សម្គាល់ថា៖ អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺខាងលើ សរុបមានចំនួន ៥៧នាក់ ដែលនៅក្នុងចំនួននេះ មានបុគ្គលខាងលើនេះផងដែរ។ រីឯ អ្នកដំណើរចំនួន ៥៦នាក់ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ នោះ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញចំនួន ១៩នាក់ សណ្ឋាគារ មួយទៀតក្នុងរាជធានីភ្នំពេញចំនួន ២២នាក់ នៅស្ថានទូតរុស្ស៊ីចំនួន ១០នាក់ និងនៅស្ថានទូតចិន ០៥នាក់។

- **ស្ត្រីជនជាតិខ្មែរអាយុ ៥៦ឆ្នាំ** មានអាសយដ្ឋាននៅសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប និងនៅបុរីប៉េងហួត ផ្លូវ៦០ម៉ែត រាជធានីភ្នំពេញ ដែលគាត់មានអាការៈមិនស្រួលខ្លួន (មានចេញពេតសញ្ញាផ្តាសាយចំនួន ៣ថ្ងៃ) ក៏បានទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដើម្បីពិនិត្យជំងឺ ហើយត្រូវបានគ្រូពេទ្យយកវត្ថុសំណាករបស់គាត់ទៅពិនិត្យ ដែលលទ្ធផលវិភាគផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្ន អ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

- **ស្វាមីស្ត្រីអាយុ ៥៦ឆ្នាំខាងលើ** ជាអគ្គនាយកពន្ធនាគារនៃក្រសួងមហាផ្ទៃ រួមជាមួយ**សមាជិកគ្រួសារចំនួន ០៤នាក់**ទៀតដែលនៅផ្ទះជាមួយគ្នា (ស្ត្រីអាយុ ៣៦ឆ្នាំ, កុមារីអាយុ ១២ឆ្នាំ, បុរសអាយុ ៣៦ឆ្នាំ, និងបុរសអាយុ ៣០ឆ្នាំ) បានធ្វើតេស្តវត្ថុសំណាក ដោយទទួលបានលទ្ធផលវិជ្ជមានវីរុសកូវីដ-១៩ ពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ហើយបច្ចុប្បន្ន ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**៤. វិធានការ និងការណែនាំរបស់ក្រសួងសុខាភិបាល**

ក្រសួងសុខាភិបាល សូមជម្រាបជូនដល់អ្នកដែលប៉ះពាល់ជាមួយអ្នកជំងឺ (ស្វាមី និងភរិយា ព្រមទាំងក្រុមគ្រួសារ ០៤នាក់) ខាងលើទាំងអស់ ចាំបាច់ត្រូវធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃនៅតាមផ្ទះរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងនៅមណ្ឌលចត្តាឡីស័កនៅខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តបន្ទាយមានជ័យ (សម្រាប់អ្នកដែលប៉ះពាល់នៅតាមខេត្ត) និងអនុវត្តន៍ទៅតាមសារសម្លេងណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាយប់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ និងរបស់ក្រសួងសុខាភិបាលឲ្យបានហ្មត់ចត់ជាទីបំផុត ហើយកុំដើរចេញក្រៅផ្ទះ ឬចេញពីមណ្ឌលចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនេះឲ្យសោះ ដើម្បីទប់ស្កាត់ការចម្លងវីរុសដ៏កាចសាហាវនេះ ពីមនុស្សម្នាក់ទៅម្នាក់ និងកុំឲ្យមានការរាតត្បាតទ្រង់ទ្រាយធំនៅក្នុងសហគមន៍។ អាជ្ញាធរថ្នាក់ក្រោមជាតិ និងមន្ទីរសុខាភិបាលខេត្តដែលពាក់ព័ន្ធ ត្រូវបន្តរុករកស្រាវជ្រាវរកអ្នកប៉ះពាល់ និងធ្វើការតាមដានការងារធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃនេះ ជាបន្តទៀត ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ បន្តគ្នា ក្នុងលក្ខណៈទ្រង់ទ្រាយធំនៅសហគមន៍ផងដែរ។ រីឯ ផ្សារទំនើបអ៊ីអនទី១ ត្រូវបានបិទជា បណ្តោះអាសន្នក្នុងរយៈពេល ២-៣ថ្ងៃសិន ដើម្បីធ្វើការស្រាវជ្រាវរកអ្នកប៉ះពាល់។

ដោយឯកឧត្តមអគ្គនាយកពន្ធនាគារនៃក្រសួងមហាផ្ទៃ មានការជួបប្រជុំជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួននៅសប្តាហ៍កន្លងទៅនេះ និងដោយសារអ្នកជំងឺមានប្រវត្តិធ្វើដំណើរទៅខេត្តសៀមរាប និងទៅទីកន្លែងផ្សេងៗទៀត ដូចជាផ្សារទំនើបអ៊ីអនទី១ រាជធានីភ្នំពេញ និងខេត្តបន្ទាយមានជ័យ ជាដើម ហើយអ្នកប៉ះពាល់ផ្ទាល់មួយចំនួនក៏បានធ្វើដំណើរទៅខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងអាចមានខេត្តផ្សេងៗទៀត (កំពុងស្រាវជ្រាវបន្ត) នៅក្នុងរយៈពេលមួយសប្តាហ៍កន្លងទៅនេះ ក្រសួងសុខាភិបាល បានរៀបចំក្រុមការងារយក

វត្ថុសំណាក ហើយសូមអំពាវនាវដល់បុគ្គលទាំងអស់ដែលបានពាក់ព័ន្ធ ឬបានប្រាស្រ័យទាក់ទងជាមួយអ្នកជំងឺខាងលើ សូមអញ្ជើញមកធ្វើតេស្តនៅបរិវេណក្រសួងមហាផ្ទៃ នៅបរិវេណផ្សារទំនើបអ៊ីអនទី១រាជធានីភ្នំពេញ និងនៅពន្ធធនាគារព្រៃស ចាប់ពីម៉ោង ០៧:៣០នាទីព្រឹកនៃថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០។ ដោយឡែក ក្រុមការងារក្រសួង និងយកវត្ថុសំណាកនៅកន្លែងផ្សេងៗទៀត ក្នុងករណីចាំបាច់។ រីឯអ្នកដែលពាក់ព័ន្ធនឹងអ្នកជំងឺនៅខេត្តសៀមរាប សូមអញ្ជើញទៅធ្វើតេស្តនៅសាលាគរុកោសល្យខេត្តសៀមរាប ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០ព្រឹក ដែលរៀបចំដោយមន្ទីរសុខាភិបាលខេត្តសៀមរាប។ នៅតាមបណ្តាខេត្តពាក់ព័ន្ធ សូមអញ្ជើញធ្វើទំនាក់ទំនងជាមួយមន្ទីរសុខាភិបាលខេត្ត ដើម្បីធ្វើតេស្ត បានទាន់ពេលវេលា ជាការចូលរួមទាំងអស់គ្នាក្នុងការកាត់ផ្តាច់ការចម្លងវីរុសកូវីដ-១៩ បន្តទៀតនៅសហគមន៍ផងដែរ។

សម្រាប់បងប្អូនប្រជាពលរដ្ឋទូទៅ សូមបន្តការរស់នៅធម្មតាតាមបែបគន្លងថ្មី ដោយពាក់ម៉ាស់ (ក្នុងករណីចាំបាច់) ជាពិសេសនៅក្នុងកាលទេសៈនេះ សូមមើលការខុសត្រូវកូនចៅខ្លួនដោយកុំឲ្យដើរចេញក្រៅផ្ទះរហេតរហូតបើមិនចាំបាច់ តែបើអាក់ខានមិនបាននោះ នៅពេលចេញដើរ ត្រូវពាក់ម៉ាស់ជាប់ជានិច្ច ហើយសូមកុំឲ្យមានការជួបជុំគ្នាកុះករច្រើនពេក (កាត់បន្ថយជាអតិបរិមានូវចំនួនមនុស្សជួបជុំគ្នា) ត្រូវលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាត ឬជាមួយអាល់កុល ឬទឹកដែលសម្រាប់លាងដៃឲ្យបានញឹកញាប់ កុំយកដៃដែលមិនបានលាងសម្អាត មកប៉ះផ្ទៃមុខមាត់របស់ខ្លួន និងត្រូវរក្សាសុវត្ថិភាពសង្គម និងសុវត្ថិភាពបុគ្គលឲ្យលើសពីមួយម៉ែត្រកន្លះឡើងទៅជាចាំបាច់។ ពេលនេះ ជាដំណាក់កាលសំខាន់បំផុត ដែលប្រជាជនទាំងអស់ សូមចូលរួមសាមគ្គីគ្នាក្នុងការអនុវត្តន៍វិធានការសុខាភិបាលដ៏មានសារៈសំខាន់នេះ ដើម្បីទប់ស្កាត់ការចម្លងរាលដាលក្នុងសហគមន៍ក្នុងទ្រង់ទ្រាយធំ និងដើម្បីបងប្អូនអាចបន្តការរស់នៅជាធម្មតាតាមបែបគន្លងថ្មី។ សូមកុំភ្លេចវីរុសកូវីដ-១៩ ព្រោះវីរុសកូវីដ-១៩ មិនទាន់ទៅណាឆ្ងាយពីយើងនៅឡើយទេ ហើយ វីរុសដ៏កាចសាហាវនេះ ក៏មិនភ្លេចយើងដែរ បើយើងធ្វេសប្រហែស វីរុសកាចសាហាវនេះ នឹងវ៉ៃលុកសរីរាង្គកាយយើងហើយ។ ដូច្នេះ មានតែវិធីការពារខ្លួនឲ្យបានខ្ជាប់ខ្ជួនតាមការណែនាំខាងលើនេះទេ ដែលអាចជួយទប់ស្កាត់បានជាអតិបរិមានូវការចម្លងពីបុគ្គលទៅបុគ្គល ពីបុគ្គលទៅក្រុមគ្រួសារខ្លួន និងមិនចម្លងពីបុគ្គលរាតត្បាតក្នុងសហគមន៍ទ្រង់ទ្រាយធំ។

ប្រសិនបើមានបងប្អូនប្រជាពលរដ្ឋណាម្នាក់មានបញ្ហាសុខភាពដែលសង្ស័យជាជំងឺកូវីដ-១៩ សូមរាយការណ៍ទៅក្រុមគ្រូពេទ្យជាបន្ទាន់ ដោយសូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងសុខាភិបាល **លេខ១១៥** ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាលតាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ១៤កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា